


# គោលការណ៍ ១០ ចំណុច

## សម្រាប់គ្រប់គ្រងការជួបប្រជុំឲ្យបានត្រឹមត្រូវ

# បញ្ជីត្រួតពិនិត្យ ការអនុវត្ត

បញ្ជីត្រួតពិនិត្យជាជំហានៗសម្រាប់ឃ្លាំមើលការអនុវត្តអនុសាសន៍ជាក់ស្តែងស្តីពីរបាយការណ៍គ្រប់គ្រងការជួបប្រជុំ (A/HRC/31/66) ដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ លោក **ម៉ៃណា គីអាយ** និង លោក **គ្រីស្តូហ្វ ហេនស៍**។


freeassembly.net

Published Sept. 2016 by
UN Special Rapporteur
Maina Kiai

## បញ្ជីត្រួតពិនិត្យ

# ការអនុវត្ត

បញ្ជីត្រួតពិនិត្យជាជំហានៗសម្រាប់ឃ្លាំមើលការអនុវត្តអនុសាសន៍ជាក់ស្ដែងស្ដីពីរបាយការណ៍គ្រប់គ្រងការជួបប្រជុំ (A/HRC/31/66) ដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ លោក **ម៉ៃណា គីអាយ** និង លោក **គ្រីស្ទហ្វ ហេនស៍**។

បោះពុម្ពផ្សាយក្នុងខែកញ្ញាឆ្នាំ ២០១៦ ដោយអ្នករាយការណ៍ពិសេស
ស្ដីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម

# អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ

## ស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម

## អំពីអាណត្តិរបស់អ្នករាយការណ៍ពិសេស

នីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សគឺជាអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យទាំងឡាយដែលមានអាណត្តិរាយការណ៍ និងផ្តល់ប្រឹក្សាយោបល់ស្តីពីសិទ្ធិមនុស្ស ពីទិដ្ឋភាពទស្សនៈវិស័យតាមប្រធានបទ ឬតាមស្ថានភាពជាក់លាក់របស់ប្រទេសមួយ។ ប្រព័ន្ធនីតិវិធីពិសេសគឺជាធាតុស្នូលមួយនៃក្បាលម៉ាស៊ីនសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងគ្របដណ្តប់លើគ្រប់សិទ្ធិមនុស្សទាំងអស់៖ សិទ្ធិពលរដ្ឋ វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គម។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនាឆ្នាំ ២០១៦ មានអាណត្តិតាមប្រធានបទចំនួន៤២ និងអាណត្តិតាមប្រទេសចំនួន១៤។

អាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងការបង្កើតសមាគម (បច្ចុប្បន្ននេះ គឺលោក ម៉ៃណា គីអាយ (ជនជាតិកេនយ៉ា) ត្រូវបានបង្កើតឡើងនៅខែតុលាឆ្នាំ២០១០ ដើម្បីពិនិត្យ ឃ្លាំមើល ផ្តល់ប្រឹក្សាយោបល់ និងរាយការណ៍ជាសាធារណៈអំពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគមនៅទូទាំងពិភពលោក។

អាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីការសម្លាប់ក្រៅច្បាប់ ឬការសម្លាប់ភ្លាមៗ ឬការសម្លាប់តាមអំពើចិត្ត (បច្ចុប្បន្ន គឺអ្នកស្រី អាជនេស កាលឡាម៉ាដ ជនជាតិបារាំង ដែលអតីតគឺលោក គ្រីស្តូហ្វ ហេនស៍ ជនជាតិអាហ្វ្រិកខាងត្បូង ឆ្នាំ២០១០-២០១៦) ពិនិត្យស្ថានភាពនៃការសម្លាប់ក្រៅច្បាប់ ឬការសម្លាប់ភ្លាមៗ ឬការសម្លាប់តាមអំពើចិត្ត នៅគ្រប់ករណីទាំងអស់ និងដោយហេតុផលអ្វីក៏ដោយនៅទូទាំងពិភពលោក។



### អំពីលោក ម៉ៃណា គីអាយ

លោក ម៉ៃណា គីអាយ (កេនយ៉ា) បានចំណាយពេលម្ភៃឆ្នាំចុងក្រោយនេះ ធ្វើយុទ្ធនាការដើម្បីសិទ្ធិមនុស្ស និងកំណែទម្រង់រដ្ឋធម្មនុញ្ញនៅប្រទេសកេនយ៉ា- អ្វីដែលគួរឲ្យកត់សំគាល់នោះគឺ ក្នុងនាមជាស្ថាបនិក និងជានាយកប្រតិបត្តិនៃគណៈកម្មការសិទ្ធិមនុស្សក្រៅផ្លូវការនៃប្រទេសកេនយ៉ាហើយបន្ទាប់មកជាប្រធានគណៈកម្មការជាតិសិទ្ធិមនុស្សកេនយ៉ា (២០០៣-២០០៨) ដែលកាលនោះលោកទទួលបានកេរ្តិ៍ឈ្មោះល្បីល្បាញថ្នាក់ជាតិ ចំពោះការតស៊ូមតិដ៏ក្លាហាន និងមានប្រសិទ្ធភាពរបស់លោកប្រឆាំង នឹងអំពើពុករលួយរបស់រដ្ឋាភិបាលក្នុងការគាំទ្រដល់កំណែទម្រង់នយោបាយ និងប្រឆាំងនឹងនិទណ្ឌភាព ក្រោយពីមានអំពើហិង្សាមួយបានញាំញីប្រទេសកេនយ៉ាក្នុងឆ្នាំ២០០៨។ លោកបានបម្រើការងារជាអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម ចាប់តាំងពីឆ្នាំ២០១១រហូតមក។



### អំពីលោក គ្រីស្តូហ្វ ហេនស៍

លោក គ្រីស្តូហ្វ ហេនស៍ (អាហ្វ្រិកខាងត្បូង) ជានាយក វិទ្យាស្ថានច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀបនៅអាហ្វ្រិកនិងជាសាស្ត្រាចារ្យច្បាប់សិទ្ធិមនុស្សនៅសាកលវិទ្យាល័យ ព្រីតូរីយ៉ា ដែលនៅទីនោះលោកបានដឹកនាំមជ្ឈមណ្ឌលសិទ្ធិមនុស្សផងដែរ និងបានចូលរួមក្នុងគំនិតផ្តួចផ្តើមស្តីពីសិទ្ធិមនុស្សដែលមានវិសាលភាពធំធេងនៅអាហ្វ្រិក។ លោកបានផ្តល់យោបល់ដល់ស្ថាប័នថ្នាក់អន្តរជាតិថ្នាក់តំបន់ និងថ្នាក់ជាតិជាច្រើនអំពីបញ្ហាសិទ្ធិមនុស្ស។ លោកបានបម្រើការជាអ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីការសម្លាប់ក្រៅច្បាប់ ឬការសម្លាប់ភ្លាមៗ ឬការសម្លាប់តាមអំពើចិត្តចាំពីឆ្នាំ ២០១០ ដល់ ២០១៦)។ កាលពីពេលថ្មីៗនេះ លោកបានជាប់ឆ្នោតជាសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិចាប់ពីឆ្នាំ ២០១៧។


សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖

freeassembly@ohchr.org or info@freeassembly.net

វិបសាយ៖ http://freeassembly.net/ ហ្វេសប៊ុក៖ https://www.facebook.com/mainakiai.sr ទ្វីតធ៊ី៖ https://twitter.com/MainaKiai_UNSR

វិបសាយផ្លូវការរបស់ការិយាល័យ OHCHR៖ http://www.ohchr.org/EN/Issues/AssemblyAssociation/Pages/SRFreedomAssemblyAssociationIndex.aspx



ការផលិតរបាយការណ៍នេះបានពីមូលនីធិសប្បុរសរបស់ក្រសួងការបរទេសនៃរាជរដ្ឋាភិបាលនរវេ

# មាតិការឿង


p2 **អំពីបញ្ជីត្រួតពិនិត្យ**

p3 **គោលការណ៍ណែនាំលេខមួយ៖**
កាតព្វកិច្ចរបស់រដ្ឋក្នុងការគោរព
និងធានាសិទ្ធិ

p5 **គោលការណ៍ណែនាំលេខពីរ៖**
សិទ្ធិមិនអាចផ្ទេរ ឬលក់ដូរបានក្នុងការ
ចូលរួមជួបប្រជុំដោយសន្តិវិធី

p7 **គោលការណ៍ណែនាំលេខបី៖**
ការរិតត្បិតមានកម្រិតលើសិទ្ធិជួប
ប្រជុំដោយសន្តិវិធី

p9 **គោលការណ៍ណែនាំលេខបួន៖**
ការសម្របសម្រួលសិទ្ធិ
ជួបប្រជុំដោយសន្តិវិធី

p11 **គោលការណ៍ណែនាំលេខប្រាំ៖**
ការប្រើប្រាស់កម្លាំង

p14 **គោលការណ៍ណែនាំលេខប្រាំមួយ៖**
សិទ្ធិសង្កេតការណ៍ ឃ្លាំមើល
និងកត់ត្រាការជួបប្រជុំ

p16 **គោលការណ៍ណែនាំប្រាំពីរ៖**
ការប្រមូលព័ត៌មានផ្ទាល់ខ្លួន
និងសិទ្ធិឯកជន

p18 **គោលការណ៍ណែនាំលេខប្រាំបី៖**
សិទ្ធិទទួលបានព័ត៌មាន

p20 **គោលការណ៍ណែនាំលេខប្រាំបួន៖**
ការទទួលខុសត្រូវរបស់
សហគ្រាសធុរកិច្ច

p21 **គោលការណ៍ណែនាំលេខដប់៖**
គណនេយ្យភាពរដ្ឋ

p23 **ពិន្ទុសិទ្ធិជួបប្រជុំរបស់ប្រទេសអ្នក**

# អំពីបញ្ជី
# ត្រួតពិនិត្យនេះ

លទ្ធភាពជួបប្រជុំ និងធ្វើសកម្មភាពជាសមូហភាពគឺសំខាន់សម្រាប់ការអភិវឌ្ឍលិទ្ធិប្រជាធិបតេយ្យ សេដ្ឋកិច្ច សង្គម និងបុគ្គលចំពោះការសម្ដែងគំនិត និងចំពោះការជំរុញឲ្យមានការចូលរួមពីប្រជាពលរដ្ឋ។ ប៉ុន្តែទោះបីជាការជួបប្រជុំដើរតួនាទីកាន់តែសំខាន់ឡើងៗនៅលើពិភពលោកនាពេលបច្ចុប្បន្ននេះក្តី ក៏មានពេលខ្លះនៅខ្វះការយល់ដឹងច្បាស់លាស់អំពីច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលកំពុងអនុវត្ត។

ដើម្បីឲ្យកាន់តែច្បាស់ថែមទៀតនោះ នៅក្នុងឆ្នាំ ២០១៤ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានស្នើឲ្យអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម លោក ម៉ៃណា គីអាយ និងអ្នករាយការណ៍ពិសេសស្តីពីការសម្លាប់ក្រៅច្បាប់ ឬការសម្លាប់ភ្លាមៗ ឬការសម្លាប់តាមអំពើចិត្ត លោក គ្រីស្តូហ្វ ហេនស៍ រៀបចំរបាយការណ៍រួមគ្នាមួយ ស្តីពីការគ្រប់គ្រងការជួបប្រជុំឲ្យបានត្រឹមត្រូវ។ របាយការណ៍ (A/HRC/31/66) នោះត្រូវបានបោះពុម្ពផ្សាយកាលពីខែមីនាឆ្នាំ២០១៦ និងបានចងក្រងអនុសាសន៍ជាក់ស្តែងជាច្រើន - ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកជំនាញជាង ១០០នាក់ និងជាមួយរដ្ឋជាសមាជិក អ.ស.ប ជាង ៥០ រដ្ឋ - សម្រាប់គ្រប់គ្រងការជួបប្រជុំ។

បញ្ជីត្រួតពិនិត្យនេះគឺជាឯកសារអមជាមួយរបាយការណ៍នោះ ដែលត្រូវបានបង្កើតឡើងជាឧបករណ៍មួយ ងាយស្រួលប្រើប្រាស់ដើម្បី(១) កំណត់ថាតើអនុសាសន៍ជាក់ស្តែងណាខ្លះនៅក្នុងរបាយការណ៍នេះ មានរួចហើយនៅកម្រិតជាតិ និង (២) ជួយវាយតម្លៃថាតើអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋានគ្រប់គ្រងការជួបប្រជុំបានល្អកម្រិតណា។ នេះជាជំហានដំបូងដ៏សំខាន់មួយសម្រាប់តួអង្គទាំងឡាយដែលមានបំណងពង្រឹងដំណើរ ការអនុវត្តអនុសាសន៍ទាំងនេះ។ ឯកសារអមទីពីរ ដែលមានចំណងជើងថា ការប្រើប្រាស់កម្រងអនុសាសន៍ជាក់ស្តែងស្តីពីការគ្រប់គ្រងការជួបប្រជុំឲ្យបានត្រឹមត្រូវ(A/HRC/31/66)៖ គឺជាមគ្គុទ្ទេសមួយសម្រាប់សង្គមស៊ីវិល (នៅថ្ងៃខាងមុខ) ផ្តល់នូវមតិយោបល់ ឧបករណ៍ និងវិធីសាស្ត្រសម្រាប់ប្រមូលភស្តុតាងពាក់ព័ន្ធ និងធ្វើឲ្យមានការផ្លាស់ប្តូរក្នុងគោលនយោបាយ និងការអនុវត្តជាក់ស្តែងរបស់រដ្ឋ។
បញ្ជីត្រួតពិនិត្យនេះ មានសូចនាករចំនួន១០០ - ដែលបានចាត់ប្រភេទទៅតាមគោលការណ៍សំខាន់ៗចំនួន១០ ទាក់ទងនឹងការអនុវត្តអនុសាសន៍របស់អ្នករាយការណ៍ពិសេស។ សូចនាករទាំងនេះ មានវិសាលគមទាំងមូលសម្រាប់ "ការគ្រប់គ្រងការជួបប្រជុំ" ដោយយកមកពិចារណា និងរាប់បញ្ចូលនូវសកម្មភាព និងវិធានការនៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលកើតមានការជួបប្រជុំ ឬការតវ៉ា។ សូចនាករទាក់ទងនឹងបទដ្ឋានអន្តរជាតិពាក់ព័ន្ធដូចនេះ មិនត្រូវបានដាក់បញ្ចូលទេ ប៉ុន្តែត្រូវបានសង្ខេបនៅខាងដើមនៃផ្អែកនីមួយៗ។

អ្នកប្រើប្រាស់បញ្ជីត្រួតពិនិត្យនេះ អាចដាក់ពិន្ទុការអនុវត្តរបស់ប្រទេសខ្លួន ចាប់ពីពិន្ទុ១ ដល់ពិន្ទុ១០០ ដោយតាមមើលលេខសូចនាករដែលបានអនុវត្ត។ ប្រអប់ដាក់ពិន្ទុ មាននៅចុងបញ្ចប់នៃជំពូកនីមួយៗដែលមានសន្លឹកពិន្ទុចុងក្រោយនៅលើទំព័រ២៣។ យើងស្នើឲ្យអ្នកទ្វីត(Tweet) មកយើងនូវសន្លឹកពិន្ទុរបស់អ្នកមកកាន់៖
@MainaKiai_UNSR - ឬ អ៊ីមែលវាមកកាន់៖
info@freeassembly.net.

# គោលការណ៍ណែនាំ ទីមួយ

## “ រដ្ឋទាំងឡាយត្រូវគោរព និងធានាសិទ្ធិទាំងអស់របស់បុគ្គលក្នុងការចូលរួមក្នុងការជួបប្រជុំ”

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ (សូមមើលរបាយការណ៍នេះត្រង់កថាខណ្ឌទី១៤-ទី១៦)៖**

•រដ្ឋទាំងឡាយត្រូវគោរពនិងធានាសិទ្ធិរបស់មនុស្សគ្រប់រូប។

•រដ្ឋទាំងឡាយត្រូវគោរពនិងធានាសិទ្ធិដោយគ្មានការរើសអើងផ្អែកលើហេតុផលណាមួយដែលបានហាមឃាត់។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ១៧(ក) | រដ្ឋបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ | |
| ១៧(ក) | រដ្ឋបានផ្តល់សច្ចាប័នលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប។ | |
| ១៧(ក) | រដ្ឋបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាស្នូលសិទ្ធិមនុស្សអន្តរជាតិដែលនៅសល់ចំនួន១៦។ | |
| ១៧(ក) | រដ្ឋបានផ្តល់សច្ចាប័នលើលិខិតឧបករណ៍ថ្នាក់តំបន់ពាក់ព័ន្ធ។ | |
| ១៧(ក) | ច្បាប់បញ្ញត្តិការសន្មត់វិជ្ជមានមួយជាប្រយោជន៍ដល់ការជួបប្រជុំដោយសន្តិវិធី។ | |
| ១៧(ក) | ច្បាប់ការពារសិទ្ធិបូរណភាពរូបកាយ (រាប់ទាំងសិទ្ធិរស់រានមានជីវិត)។ | |
| ១៧(ក) | ច្បាប់ការពារសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី។ | |
| ១៧(ក) | ច្បាប់ការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម។ | |
| ១៧(ក) | ច្បាប់ការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ | |
| ១៧(ខ) | ច្បាប់ទាំងអស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការជួបប្រជុំ ត្រូវបានតាក់តែងបានច្បាស់លាស់ និងមានលក្ខណៈស្របទៅវិញទៅមក។ | |
| ១៧(ខ) | ច្បាប់ទាំងអស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការជួបប្រជុំ ស្របទៅនឹងបទដ្ឋានអន្តរជាតិ។ | |
| ១៧(ខ) | ករណីមានភាពមិនច្បាស់លាស់ណាមួយកើតមាននៅពេលតាក់តែងសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងការជួបប្រជុំ បញ្ញត្តិពាក់ព័ន្ធត្រូវបានបកស្រាយជាប្រយោជន៍ដល់អ្នកដែលមានបំណងប្រាថ្នាអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួនក្នុងការជួបប្រជុំដោយសន្តិវិធី។ | |

* ចំនួនអនុសាសន៍ដែលយោងទៅលេខកថាខ័ណ្ឌក្នុងរបាយការណ៍ទាំងមូលA/HRC/31/66

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ១៧(គ) | រដ្ឋមានផែនការសកម្មភាពជាតិបច្ចុប្បន្នភាព ដើម្បីណែនាំដល់ការអនុវត្តអនុសាសន៍ ជាក់ស្តែងបច្ចុប្បន្ន និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធដល់ការគ្រប់គ្រងការជួបប្រជុំ។ | |
| ១៧(ឃ) | រដ្ឋត្រូវផ្តល់ការគាំទ្រចាំបាច់ដល់អាជ្ញាធរ និងការត្រួតពិនិត្យគ្រប់គ្រាន់លើអាជ្ញាធរក្នុងការ គ្រប់គ្រងការជួបប្រជុំ នៅគ្រប់កម្រិតនៃរដ្ឋាភិបាល។ នេះរាប់ទាំងការផ្តល់ការបណ្តុះបណ្តាល ធនធានមនុស្ស និងថវិកាគ្រប់គ្រាន់តាមការចាំបាច់។ | |
| ១៧(ង) | ថ្នាក់ដឹកនាំនយោបាយ និងថ្នាក់ដឹកនាំដទៃផ្សេងទៀត បានទទួលស្គាល់ជាសាធារណៈថា មានបន្ទប់សម្រាប់ការបញ្ចេញមតិយោបល់ផ្សេងគ្នា និងលើកកម្ពស់វប្បធម៌នៃការអត់ឱន។ | |

**គោលការណ៍ណែនាំទីមួយ៖**
**លេខសូចនាករដែលបានបំពេញ (ក្នុងចំណោម១៥)** → ☐

# គោលការណ៍ណែនាំ ទីពីរ

"មនុស្សគ្រប់រូបមានសិទ្ធិដែលមិនអាចដកហូតបាន ក្នុងការចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធី"

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ** (**សូមមើលរបាយការណ៍ ត្រង់កថាខណ្ឌទី១៨-២៧**)៖

• ការជួបប្រជុំ គួរតែបានសន្មត់ថាស្របច្បាប់ ស្ថិតក្នុងដែនកំណត់ដែលបានអនុញ្ញាតដូចមានចែងក្នុងមាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។ សុខសន្តិភាពនៃការជួបប្រជុំមួយ គួរតែបានសន្មត់ ហើយគួរតែបានធ្វើការបកស្រាយក្នុងន័យទូលាយនូវពាក្យ "សន្តិវិធី" ។

•កាតព្វកិច្ចរបស់រដ្ឋក្នុងការជួយសម្រួល និងការពារការជួបប្រជុំរាប់ទាំងការជួបប្រជុំកើតចេញពីឆន្ទៈភ្លាមៗ ការជួបប្រជុំពេលដំណាលគ្នា និងការតវ៉ាការប្រឆាំង។ ការជួបប្រជុំ រួមបញ្ចូលទាំង ការជួបប្រជុំកើតចេញពីឆន្ទៈភ្លាមៗ និងការតវ៉ាប្រឆាំង គួរតែបានជួយសម្រួលតាមដែលអាចធ្វើបាន ដើម្បីឲ្យកើតមានឡើងស្របតាមគោលដៅ និងបំណងប្រាថ្នារបស់ពួកគេ។

•កាតព្វកិច្ចរបស់រដ្ឋក្នុងការជួយសម្រួល លាតសន្ធឹងពីការចាត់វិធានការដើម្បីការពារអ្នកទាំងឡាយ ដែលអនុវត្តសិទ្ធិ របស់ខ្លួនឲ្យរួចផុតពីអំពើហិង្សា ឬការជ្រៀតជ្រែករំខាន។

• អ្នករៀបចំ មិនគួរត្រូវបានគេដាក់ឲ្យទទួលខុសត្រូវ ចំពោះឥរិយាបថខុសច្បាប់របស់អ្នកដទៃឡើយ។

•គ្មាននណាម្នាក់ គួរត្រូវបានគេដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬទទួលខុសត្រូវផ្នែករដ្ឋបាល ចំពោះសកម្មភាពដែលគ្រាន់តែជាការរៀបចំ ឬការចូលរួមក្នុងការតវ៉ាដោយសន្តិវិធីឡើយ។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ២៨(ខ) | រដ្ឋមិនចាំបាច់តម្រូវ-ក្នុងច្បាប់ ឬក្នុងការអនុវត្តជាក់ស្តែង- ឲ្យអ្នករៀបចំការជួបប្រជុំសុំការអនុញ្ញាតជាមុន ដើម្បីធ្វើការជួបប្រជុំនោះឡើយ។ | |
| ២៨(គ) | ប្រសិនជាមានការអនុវត្តប្រព័ន្ធជូនដំណឹងជាមុន នោះត្រូវមានការសន្មត់មួយដែលជាប្រយោជន៍ដល់ការជួបប្រជុំ។ | |
| ២៨(គ) | ប្រសិនជាមានការអនុវត្តប្រព័ន្ធជូនដំណឹងជាមុន នោះការកម្រិតកំណត់តូចចង្អៀតត្រូវតែដាក់លើឆន្ទានុសិទ្ធិរបស់អាជ្ញាធរ ក្នុងការរិតត្បិតដល់ការជួបប្រជុំ។ | |
| ២៨(គ) | ប្រសិនជាមានការអនុវត្តប្រព័ន្ធជូនដំណឹងជាមុន នោះការវាយតម្លៃអំពីភាពសមាមាត្រ ត្រូវតែធ្វើ។ | |
| ២៨(ឃ) | ការជូនដំណឹងអំពីការជួបប្រជុំ មិនត្រូវមានរយៈពេលច្រើនថ្ងៃឡើយ គឺក្នុងរយៈពេល ៤៨ម៉ោង ជាការល្អ។ | |

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ២៨(គ) | ប្រសិនជាមានការអនុវត្តប្រព័ន្ធជូនដំណឹងជាមុន នោះប្រព័ន្ធនេះមិនអាចឲ្យមានលក្ខណៈការិយាធិបតេយ្យហួសហេតុពេកឡើយ។ ការពិចារណាអាចដាក់បញ្ចូល៖<br>•តើមានកន្លែងជាច្រើនសម្រាប់ការជូនដំណឹង រាប់ទាំងតំបន់ផ្សេងៗនៅក្រៅទីក្រុងដែរឬទេ?<br>•តើមានជំនួយពីបុគ្គលផ្ទាល់សម្រាប់ការជូនដំណឹងដែរឬទេ?<br>•តើទម្រង់សម្រាប់ការជូនដំណឹងអាចរកបាន ច្បាស់លាស់ និងមានច្រើនភាសា ដែរឬទេ?<br>•តើការជូនដំណឹងអាចធ្វើតាមអនឡាញ និងដោយបុគ្គលផ្ទាល់ បានដែរ ឬទេ? | |
| ២៨(ឃ) | ក្រោយពេលជូនដំណឹងរួចហើយ ការជួបប្រជុំអាចដំណើរការទៅបានមិនចាំបាច់មានការឆ្លើយតបពីអាជ្ញាធរទៅនឹងការជូនដំណឹងឡើយ។ | |
| ២៨(ង) | ការជូនដំណឹងចាត់ទុកថាបានបំពេញ នៅពេលដែលលិខិតជូនដំណឹងមួយ ផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់អាជ្ញាធរដើម្បីកំណត់ឲ្យបានត្រឹមត្រូវនូវកាលបរិច្ឆេទ ពេលវេលា និងទីតាំងនៃការជួបប្រជុំ ហើយប្រសិនជាពាក់ព័ន្ធ ព័ត៌មានទំនាក់ទំនងរបស់អ្នករៀបចំ ក៏ត្រូវទទួលបានផងដែរ។ | |
| ២៨(ច) | ប្រសិនជាការជូនដំណឹងត្រូវបានស្នើសុំ សម្រាប់ការជួបប្រជុំពីរ ឬច្រើននៅទីកន្លែងនិងពេលវេលាតែមួយ រដ្ឋត្រូវធ្វើការវាយតម្លៃឲ្យបានហ្មត់ចត់អំពីហានិភ័យណាមួយ និងបង្កើតយុទ្ធសាស្ត្រដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។ | |
| ២៨(ឆ) | ប្រសិនបើវាជាការចាំបាច់ក្នុងការដាក់ការរឹតត្បិតលើការជួបប្រជុំមួយ ឬច្រើនដែលកើតឡើងចេញពីឆន្ទៈភ្លាមៗ រដ្ឋត្រូវប្រើប្រាស់ដំណើរការមួយដើម្បីកំណត់ការរិតត្បិតទាំងឡាយតាមរយៈការព្រមព្រៀងគ្នាទៅវិញទៅមក ឬប្រសិនជាមិនអាចធ្វើទៅបាន ត្រូវធ្វើតាមរយៈដំណើរការមួយដែលមិនរើសអើង រវាងការជួបប្រជុំទាំងឡាយដែលបានស្នើសុំ។ | |

**គោលការណ៍ណែនាំទីពីរ៖**

**លេខសូចនាករដែលបានបំពេញ (ក្នុងចំណោម១០)** → ☐

# គោលការណ៍ណែនាំ ទីបី

**“ការរឹតត្បិតណាមួយដែលកម្រិតលើការជួបប្រជុំដោយសន្តិវិធី ត្រូវអនុវត្តស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ”**

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ** (**សូមអានរបាយការណ៍នេះ ត្រង់កថាខណ្ឌទី២៩-៣៥**)៖

•សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី គឺជាសិទ្ធិជាមូលដ្ឋានមួយ ហើយសេរីភាពនេះគួរតែត្រូវបានទទួលដោយគ្មានការរឹតត្បិតតាមកម្រិតវិសាលភាពធំធេងបំផុត តាមដែលអាចធ្វើបាន ។

•មានតែការរឹតត្បិតទាំងឡាយណាដែលចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ជាប្រយោជន៍ដល់សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាព ឬសីលធម៌សាធារណៈ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ហើយស្របច្បាប់ ចាំបាច់ និងសមាមាត្រនឹងគោលបំណងប៉ុណ្ណោះ អាចត្រូវអនុញ្ញាតអោយអនុវត្តបាន។

•ការរឹតត្បិតដែលបានធ្វើឡើង ត្រូវអនុលោមទៅនឹង “គោលការណ៍នីត្យានុកូល” មានន័យថាការរឹតត្បិតទាំងនោះត្រូវតែផ្អែកលើមូលដ្ឋានច្បាប់ និងផ្លូវការ ដែលមានចែងដោយច្បាប់ ដែលផ្តល់អាណត្តិ និងអំណាចឲ្យអាជ្ញាធរដែលដាក់ការរឹតត្បិត។

•ការរឹតត្បិតត្រូវតែអនុលោមទៅនឹង "គោលការណ៍សមាមាត្រ" មានន័យថាការរឹតត្បិតនោះ ត្រូវតែធ្វើឡើងសមស្រប ដើម្បីសម្រេចបាននូវតួនាទីការពាររបស់ខ្លួន។

•ការរឹតត្បិតត្រូវតែអនុលោមផងដែរទៅនឹងគោលការណ៍ចាំបាច់ មានន័យថាការរឹតត្បិតនោះត្រូវតែជាឧបករណ៍រំលោភបំពានតិចតួចបំផុត ក្នុងចំណោមការរឹតត្បិតទាំងឡាយដែលអាចសម្រេចលទ្ធផលដែលចង់បាន។

•ការរឹតត្បិតលើខ្លឹមសារនៃការជួបប្រជុំ អាចត្រូវបាននេះធ្វើឡើងស្របទៅតាមការកម្រិតទៅលើសិទ្ធិស្របតាមច្បាប់តែប៉ុណ្ណោះ។

•ការផ្តល់ហេតុផលអំពីការដាក់ការរឹតត្បិត គឺជាបន្ទុករបស់អាជ្ញាធរ។ ប្រសិនជាមានការដាក់កម្រិតណាមួយត្រូវបានធ្វើឡើង គួរតែមានជម្រើសមួយឲ្យអ្នករៀបចំស្វែងរកការពិនិត្យតាមផ្លូវតុលាការ ហើយប្រសិនពាក់ព័ន្ធត្រូវមានការពិនិត្យផ្នែករដ្ឋបាលមួយដែលឆាប់រហ័ស មានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៣៦(ក) | ច្បាប់គ្រប់គ្រងសកម្មភាពរដ្ឋទាក់ទងនឹងការជួបប្រជុំត្រូវបានតាក់តែងឲ្យបានច្បាស់លាស់ និងបញ្ចូលគោលការណ៍នីត្យានុកូល ភាពចាំបាច់ និងតេស្តអំពីសមាមាត្រ។ | |
| ៣៦(ក) | ច្បាប់ចែងយ៉ាងច្បាស់អំពីស្ថាប័នដែលមានអំណាច និងការទទួលខុសត្រូវក្នុងការទទួលបាន និងការឆ្លើយតបចំពោះការជូនដំណឹង។ | |
| ៣៦(ក) | ស្ថាប័នដែលមានអំណាច និងការទទួលខុសត្រូវក្នុងការទទួល និងការឆ្លើយតបចំពោះការជូនដំណឹង ត្រូវតែឯករាជ្យពីការជ្រៀតជ្រែកមិនចាំបាច់ ហើយមិនត្រូវបានផ្តល់ឆន្ទានុសិទ្ធិហួសហេតុឡើយ។ | |
| ៣៦(ក) | លក្ខណៈវិនិច្ឆ័យដែលស្ថាប័នមានអំណាច និងការទទួលខុសត្រូវក្នុងការទទួល និងការឆ្លើយតបចំពោះការជូនដំណឹង អាចដាក់ការរឹតត្បិតដែលស្របតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ | |

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៣៦(ក) | លក្ខណៈវិនិច្ឆ័យដែលស្ថាប័នមានអំណាច និងការទទួលខុសត្រូវក្នុងការទទួល និងការឆ្លើយតបចំពោះការជូនដំណឹង អាចធ្វើការរឹតត្បិត តែត្រូវផ្សព្វផ្សាយឲ្យដឹងជាសាធារណៈ។ | |
| ៣៦(ខ) | ការរឹតត្បិតដែលបានស្នើឡើង ត្រូវធ្វើជាលាយលក្ខណ៍អក្សរ មានបញ្ជាក់ហេតុផល និងប្រាប់ឲ្យអ្នករៀបចំបានដឹង រាប់ទាំងយុត្តិកម្មសម្រាប់ការរឹតត្បិត។ | |
| ៣៦(ខ) | អ្នករៀបចំត្រូវបានអនុញ្ញាតឲ្យធ្វើសំណើ និងឆ្លើយតបចំពោះការរិតត្បិតណាមួយដែលបានស្នើឡើង(ឧទា. ការប្ដឹងតវ៉ា) ។ | |
| ៣៦(គ) | ការរឹតត្បិតដែលបានស្នើឡើង ត្រូវបានប្រាស្រ័យទាក់ទងក្នុងក្របខ័ណ្ឌពេលវេលាមួយដែលមានចែងដោយច្បាប់ ដោយទុកពេលវេលាគ្រប់គ្រាន់សម្រាប់ការប្ដឹងតវ៉ា<br>- ឬផ្ដល់ការសម្រាលបន្ទាន់បណ្ដោះអាសន្ន<br>- ដែលត្រូវធ្វើឲ្យចប់សព្វគ្រប់មុនពេលស្នើសុំជួបប្រជុំ។ | |
| ៣៦(ឃ) | ច្បាប់ផ្ដល់ឲ្យអ្នករៀបចំនូវលទ្ធភាពទទួលបានការដោះស្រាយផ្នែករដ្ឋបាល។ | |
| ៣៦(ឃ) | ការប្រើប្រាស់ដំណោះស្រាយផ្នែករដ្ឋបាលចុងក្រោយ មិនមែនជាបុរេលក្ខខណ្ឌសម្រាប់អ្នករៀបចំក្នុងការស្វែងរកការពិនិត្យតាមផ្លូវតុលាការនោះឡើយ។ | |

**គោលការណ៍ណែនាំទីបី៖**

**លេខសូចនាករដែលបានបំពេញ (ក្នុងចំណោម១០)** →

# គោលការណ៍ណែនាំ ទីបួន

"រដ្ឋត្រូវសម្រួលដល់ការអនុវត្តសិទ្ធិជួបប្រជុំដោយសន្តិវិធី"

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ (សូមមើលរបាយការណ៍នេះ ត្រង់កថាខណ្ឌទី៣៧-៤៨)៖**

•កាតព្វកិច្ចវិជ្ជមានរបស់រដ្ឋក្នុងការធានាសិទ្ធិតម្រូវថា អាជ្ញាធរត្រូវតែសម្រួលដល់ការជួបប្រជុំ។ រដ្ឋគួររៀបចំគម្រោងឲ្យបានត្រឹមត្រូវសម្រាប់ការជួបប្រជុំ ធានាថាការធ្វើសេចក្តីសម្រេច ត្រូវតែមានតម្លាភាព និងត្រូវដាក់ចេញ នូវផែនការឧប្បត្តិហេតុផ្សេងៗ និងវិធានបង្ការទុកជាមុន។

• ទីភ្នាក់ងារ និងមន្ត្រីអនុវត្តច្បាប់គួរចាត់វិធានការសមហេតុផលគ្រប់បែបយ៉ាង ដើម្បីប្រាស្រ័យទាក់ទងជាមួយអ្នករៀបចំការជួបប្រជុំ និង/ឬអ្នកចូលរួម ទាក់ទងនឹងការប្រតិបត្តិការយាមល្បាត និងវិធានការសុវត្ថិភាព ឬសន្តិសុខ។

•កាតព្វកិច្ចរបស់រដ្ឋក្នុងការសម្រួល រាប់ទាំងការទទួលខុសត្រូវផ្តល់សេវាជាមូលដ្ឋាន រួមទាំងការចាត់ចែងចរាចរណ៍ ជំនួយឧបត្ថម្ភផ្នែកវេជ្ជសាស្ត្រ និងសេវាបោសសម្អាតជាដើម។ អ្នករៀបចំមិនគួរត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការផ្តល់ ឬការចំណាយលើសេវាបែបនេះឡើយ។

•មន្ត្រីអនុវត្តច្បាប់ត្រូវតែទទួលការបណ្តុះបណ្តាលឲ្យបានគ្រប់គ្រាន់ ក្នុងការសម្រួលដល់ការជួបប្រជុំ។

• ការឃាត់ និងការឆែកឆេរអ្នកចូលរួមក្នុងការជួបប្រជុំ មិនត្រូវធ្វើដោយបំពាន នឹងមិនត្រូវរំលោភគោលការណ៍មិនរើសអើងឡើយ។ ការឃាត់ និងការឆែកឆេរនេះ ត្រូវធ្វើតាមច្បាប់កំណត់ តាមការចាំបាច់ និងមានសមាមាត្រ។

•វិធានការបំបាត់ភ័យអន្តរាយ មិនត្រូវប្រើប្រាស់ឡើយ ប្រសិនបើគ្រោះថ្នាក់បច្ចុប្បន្នមិនបង្ហាញច្បាស់ថានឹងមានអំពើហឹង្សាកើតមាននោះទេ។

•អំណាចចាប់ខ្លួន ត្រូវតែបានអនុវត្តស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រាប់ទាំងអំណាចទាក់ទងនឹងសិទ្ធិឯកជន សេរីភាព និងសិទ្ធិទទួលបានដំណើរការនីតិវិធីស្របតាមច្បាប់។

•គ្មាននរណាម្នាក់អាចទទួលរងការចាប់ខ្លួន ឬការឃុំខ្លួនដោយបំពានឡើយ។ ប្រសិនជាមានការចាប់ខ្លួន លក្ខខណ្ឌឃុំខ្លួនត្រូវតែបំពេញតាមបទដ្ឋានអប្បបរមា ដូចមានចែងក្នុងច្បាប់អន្តរជាតិ។ ជនជាប់ឃុំត្រូវតែបានប្រព្រឹត្តទៅលើខ្លួនប្រកបដោយលក្ខណៈមនុស្សធម៌ និងដោយគោរពចំពោះសេចក្តីថ្លៃថ្នូររបស់ពួកគេ ហើយមិនត្រូវទទួលរងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក ។

•ការដាក់ពិន័យណាមួយទៅលើអ្នករៀបចំការជួបប្រជុំ ឬអ្នកចូលរួមប្រជុំ មិនត្រូវឲ្យហួសហេតុនោះឡើយ។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៤៩(ក) | ការអនុវត្តច្បាប់ ត្រូវតែមានលក្ខណៈចម្រុះ និងត្រូវតែមានតំណាងសហគមន៍ រាប់បញ្ចូលទាំង ស្ត្រី និងក្រុមភាគតិច។ | |
| ៤៩(ខ) | រដ្ឋត្រូវអនុវត្តវិធីសាស្ត្រធ្វើផែនការឲ្យបានស្របគ្នា សម្រាប់ការជួបប្រជុំ ផ្អែកលើការវាយតម្លៃការគំរាមកំហែង និងហានិភ័យ ហើយត្រូវដាក់បញ្ចូលបទដ្ឋាន និងច្បាប់ និងក្រមសីលធម៌សិទ្ធិមនុស្សអន្តរជាតិផងដែរ ។ | |

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៤៩(គ) | អាជ្ញាធរសាធារណៈ រាប់ទាំងមន្ត្រីអនុវត្តច្បាប់ ត្រូវខិតខំព្យាយាមឲ្យបានត្រឹមត្រូវដើម្បីចូលរួមធ្វើការជាមួយអ្នករៀបចំការជួបប្រជុំ និងឬអ្នកចូលរួមប្រជុំ និងអាចបង្ហាញភស្តុតាងអំពីការខិតខំទាំងនេះ។ | |
| ៤៩(ឃ) | ទីភ្នាក់ងារអនុវត្តច្បាប់ ត្រូវតែងតាំងមន្ត្រីទំនាក់ទំនងមួយរូបក្នុងអង្គភាព សម្រាប់ទាក់ទងការងារនៅមុនពេល អំឡុងពេល និងនៅក្រោយពេលជួបប្រជុំ។ | |
| ៤៩(ឃ) | មន្ត្រីទំនាក់ទំនង ត្រូវទទួលការបណ្តុះបណ្តាលជំនាញផ្នែកទំនាក់ទំនង និងការគ្រប់គ្រងទំនាស់ និងឆ្លើយតបនឹងបញ្ហាសន្តិសុខ និងឥរិយាបថរបស់នគរបាល ក៏ដូចជាការទាមទារជាក់ស្តែង និងទស្សនៈសំដែងចេញដោយអ្នកចូលរួម។ | |
| ៤៩(ឃ) | មុខងារទំនាក់ទំនងនេះ (រួមទាំងចំណុចទំនាក់ទំនងផងដែរ) គឺដាច់ដោយឡែកពីមុខងារយាមល្បាតផ្សេងទៀត។ | |
| ៤៩(ង) | យន្តការរាយការណ៍លទ្ធផលក្រោយព្រឹត្តិការណ៍សម្រាប់ការជួបប្រជុំ ត្រូវបានបង្កើតឡើងជាអចិន្ត្រៃយ៍ដើម្បីសម្រួលដល់ការរៀនសូត្រ និងធានាការការពារសិទ្ធិ។ | |
| ៤៩(ច) | មន្ត្រីអនុវត្តច្បាប់ត្រូវសហការជាមួយអ្នកមើលការខុសត្រូវ ប្រសិនជាអ្នករៀបចំសម្រេចរៀបចំឲ្យពួកគេមើលការខុសត្រូវការជួបប្រជុំ។ | |
| ៤៩(ច) | អាជ្ញាធរ មិនត្រូវតម្រូវឲ្យអ្នករៀបចំការជួបប្រជុំផ្តល់អ្នកមើលការខុសត្រូវឡើយ។ | |
| ៤៩(ឆ) | វិធានការជាមុនដែលមានលក្ខណៈរំលោភបំពាន មិនត្រូវបានប្រើប្រាស់នៅក្នុងការជួបប្រជុំឡើយ។មិនត្រូវបញ្ឈប់ ឆែកឆេរ ចាប់ខ្លួនអ្នកចូលរួមនៅពេលធ្វើដំណើរទៅកាន់កន្លែងជួបប្រជុំឡើយប្រសិនបើគ្រោះថ្នាក់បច្ចុប្បន្ន មិនបង្ហាញឲ្យឃើញច្បាស់ថា នឹងមានអំពើហិង្សាកើតមាននោះទេ។ | |

**គោលការណ៍ណែនាំទីបួន៖**
**លេខសូចនាករដែលបានបំពេញ (ក្នុងចំណោម១០)** →

# គោលការណ៍ណែនាំ ទីប្រាំ

“មិនត្រូវប្រើប្រាស់កម្លាំងទេ លុះត្រាតែក្នុងករណីចាំបាច់បំផុតដែលមិនអាចចៀសវាងបាន ហើយប្រសិនជាប្រើប្រាស់ ត្រូវតែអនុវត្តឲ្យស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ”

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ** (**សូមអានរបាយការណ៍នេះ ត្រង់កថាខណ្ឌទី៥០-៦៦**)៖

• រដ្ឋ ឬមន្ត្រីអនុវត្តច្បាប់មានកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិក្នុងការគោរព និងការពារដោយគ្មានការរើសអើងនូវសិទ្ធិរបស់អ្នកទាំងអស់ដែលចូលរួមនៅក្នុងការជួបប្រជុំ ក៏ដូចជាអ្នកឃ្លាំមើល និងអ្នកឈរមើលផងដែរ។

•គោលការណ៍នីត្យានុកូល តម្រូវឲ្យរដ្ឋបង្កើតក្របខ័ណ្ឌច្បាប់ថ្នាក់ជាតិមួយសម្រាប់ការប្រើប្រាស់កម្លាំង ជាពិសេសកម្លាំងដែលអាចបណ្តាលឲ្យគ្រោះថ្នាក់ដល់ជីវិត ដែលអនុលោមតាមបទដ្ឋានអន្តរជាតិ។

•គោលការណ៍បង្ការ ទប់ស្កាត់តម្រូវថា គ្រប់វិធានការដែលអាចធ្វើបានត្រូវតែចាត់ឡើង ក្នុងការធ្វើផែនការ និងក្នុងការធ្វើប្រតិបត្តិការទាក់ទងនឹងការជួបប្រជុំណាមួយ ដើម្បីជៀសវាងការប្រើប្រាស់កម្លាំង ឬប្រសិនបើជាការប្រើប្រាស់កម្លាំងមិនអាចជៀសវាងបាន ត្រូវកាត់បន្ថយផលវិបាកដែលបង្កគ្រោះថ្នាក់របស់វា។

• សូម្បីតែអ្នកចូលរួមក្នុងការជួបប្រជុំមួយដែលមិនសន្តិវិធី ហើយដែលនាំឲ្យបាត់បង់សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធីរបស់ពួកគេក្តី ក៏ពួកគេនៅមានសិទ្ធិទាំងអស់ដទៃផ្សេងទៀតដែលស្ថិតក្នុងដែនកំណត់ធម្មតា។ ដូច្នេះ មិនមានការជួបប្រជុំណាមួយ គួរតែត្រូវបានចាត់ថាមិនទទួលបានការការពារឡើយ។

• រដ្ឋត្រូវធានាថា មន្ត្រីអនុវត្តច្បាប់របស់ខ្លួន បានទទួលការបណ្តុះបណ្តាលជាទៀងទាត់ក្នុងការប្រើប្រាស់ និងក្នុងការសាកល្បងប្រើប្រាស់កម្លាំងស្របច្បាប់ និងក្នុងការប្រើប្រាស់អាវុធដែលបានបំពាក់ឲ្យ។

•គ្រឿងឧបករណ៍សម្រាប់មន្ត្រីអនុវត្តច្បាប់ ដែលដាក់ពង្រាយនៅក្នុងអំឡុងពេលជួបប្រជុំ គួរតែរួមបញ្ចូលគ្រឿងឧបករណ៍សមស្របសម្រាប់ការពារខ្លួន និងអាវុធសមស្របដែលបណ្តាលឲ្យមានគ្រោះតិចដល់ជិវិត។ គ្រឿងឧបករណ៍ ដែលមិនអាចធ្វើឲ្យសម្រេចគោលដៅអនុវត្តច្បាប់ស្របច្បាប់ណាមួយ ឬដែលនាំមកនូវហានិភ័យមិនចាំចាច់មិនគួរត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឡើយ។

•ការប្រើប្រាស់កម្លាំងដោយមន្ត្រីអនុវត្តច្បាប់គួរតែជាករណីពិសេស ហើយការជួបប្រជុំគួរតែត្រូវបានគ្រប់គ្រងតាមលក្ខណៈធម្មតា ដោយមិនបាច់ប្រើប្រាស់កម្លាំង។ ការប្រើប្រាស់កម្លាំងត្រូវតែគោរពតាមគោលការណ៍ស្តីពីភាពចាំបាច់ និងគោលការណ៍សមាមាត្រ។

•កាំភ្លើងអាចត្រូវបានប្រើប្រាស់តែក្នុងករណីមានការគំរាមកំហែងកើតឡើងភ្លាមៗ ដើម្បីការពារអាយុជីវិត ឬដើម្បីបង្ការរបួសស្នាមដែលគំរាមដល់អាយុជីវិត ហើយមិនមានជម្រើសណាផ្សេងដែលអាចធ្វើបាន ដូចជា ការចាប់ខ្លួន ឬការប្រើប្រាស់កម្លាំងដែលមិនបណ្តាលឲ្យស្លាប់ ដើម្បីដោះស្រាយការគំរាមកំហែងដល់ជីវិតនោះបាន។

• កាំភ្លើង មិនគួរត្រូវបានប្រើប្រាស់ដើម្បីបំបែកការជួបប្រជុំឡើយ។ ការបាញ់មិនរើសមុខទៅលើហ្វូងមនុស្ស គឺជាអំពើខុសច្បាប់។ ការប្រើប្រាស់កម្លាំងដែលបណ្តាលឲ្យស្លាប់ដោយចេតនាអាចស្របច្បាប់ទៅបាន លុះត្រាក្នុងករណីចាំបាច់បំផុតមិនជៀសវាងបាន ដើម្បីការពារអាយុជីវិតនរណាម្នាក់ពីការគំរាមកំហែងដែលកើតមានភ្លាមៗ

• របនាសម្ព័ន្ធបញ្ជាមួយច្បាស់លាស់និងតម្លាភាព ត្រូវតែបង្កើតឡើងដើម្បីកាត់បន្ថយហានិភ័យនៃអំពើហិង្សា ឬការប្រើប្រាស់កម្លាំង និងដើម្បីធានាឲ្យមានការទទួលខុសត្រូវចំពោះអំពើខុសច្បាប់ ឬការខកខានមិនបានបំពេញកាតព្វកិច្ចពីសំណាក់មន្ត្រីផ្សេងៗ។ មន្ត្រីអនុវត្តច្បាប់ត្រូវមានអត្តសញ្ញាណសំគាល់ខ្លួនច្បាស់លាស់ ឧទាហរណ៍ មានស្លាកឈ្មោះ ឬអត្តលេខសំគាល់ខ្លួន។

•រដ្ឋត្រូវបង្កើតនីតិវិធីរាយការណ៍ និងពិនិត្យរបាយការណ៍ប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយឧប្បត្តិហេតុណាមួយទាក់ទងនឹងការជួបប្រជុំ ដែលនៅក្នុងអំឡុងពេលនោះការប្រើប្រាស់កម្លាំងខុសច្បាប់កើតមានឡើង។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៦៧(ក) | មន្ត្រីអនុវត្តច្បាប់មានឧបករណ៍ចាំបាច់ដើម្បីគ្រប់គ្រងការជួបប្រជុំ ដោយមិនចាំបាច់ប្រើប្រាស់មធ្យោបាយប្រើប្រាស់កម្លាំងណាមួយ។ | |
| ៦៧(ក) | មន្ត្រីអនុវត្តច្បាប់មានការបណ្តុះបណ្តាល និងការណែនាំចាំបាច់ ដើម្បីគ្រប់គ្រងការជួបប្រជុំ ដោយមិនចាំបាច់ប្រើប្រាស់មធ្យោបាយប្រើប្រាស់កម្លាំងណាមួយ។ | |
| ៦៧(ខ) | យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងការជួបប្រជុំ សង្កត់ធ្ងន់លើយុទ្ធសាស្ត្រកាត់បន្ថយការរីករាលដាល ផ្អែកលើការទំនាក់ទំនង ការចរចា និងការចូលរួម។ | |
| ៦៧(ខ) | ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់រាប់ទាំងការណែនាំនៅមុនពេល និងនៅក្នុងពេលបំរើការងារ ទាំងនៅក្នុងថ្នាក់រៀន ទាំងនៅក្នុងការអនុវត្តជាក់ស្តែង។ | |
| ៦៧(គ) | មុនពេលធ្វើការជ្រើសរើស និងធ្វើការបញ្ជាទិញគ្រឿងឧបករណ៍ រាប់ទាំងអាវុធដែលមានគ្រោះថ្នាក់តិចដល់ជិវិត ដោយទីភ្នាក់ងារអនុវត្តច្បាប់សម្រាប់ប្រើប្រាស់ ក្នុងការជួបប្រជុំ រដ្ឋត្រូវដាក់គ្រឿងឧបករណ៍ទាំងនោះឲ្យស្ថិតក្នុងការវាយតម្លៃមួយប្រកបដោយតម្លាភាព និងដោយឯករាជ្យ ដើម្បីកំណត់ពីអនុលោមភាពទៅនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ជាពិសេសគ្រឿងឧបករណ៍ ត្រូវតែបានវាយតម្លៃពីភាពត្រឹមត្រូវ ភាពអាចជឿជាក់បាន និងសមត្ថភាពរបស់វា ដើម្បីកាត់បន្ថយគ្រោះថ្នាក់ផ្លូវកាយនិងផ្លូវចិត្ត។ | |
| ៦៧(គ) | គ្រឿងឧបករណ៍ រាប់ទាំងអាវុធមិនសូវប្រល័យ ត្រូវបានបញ្ជាទិញតែក្នុងករណីដែលមានសមត្ថភាពគ្រប់គ្រាន់ដើម្បីការបណ្តុះបណ្តាលមន្ត្រីឲ្យមាន ប្រសិទ្ធភាពអំពីការប្រើប្រាស់វាឲ្យបានត្រឹមត្រូវប៉ុណ្ណោះ។ | |
| ៦៧(ឃ) | បទបញ្ជាជាក់លាក់ និងសេចក្តីណែនាំប្រតិបត្តិការលម្អិតស្តីពីការប្រើប្រាស់ជម្រើសយុទ្ធ សាស្ត្រក្នុងការជួបប្រជុំត្រូវបានបង្កើតឡើងរាប់ទាំងអាវុធដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងប្រើប្រាស់មិនលើកមុខ មានដូចជាឧស្ម័នបង្ហូរទឹកភ្នែក និងឧបករណ៍បាញ់ទឹកជាដើម។ | |
| ៦៧(ឃ) | ការផ្សព្វផ្សាយ៖ បទបញ្ជា និងសេចក្តីណែនាំប្រតិបត្តិការលម្អិតស្តីពីការប្រើប្រាស់ជម្រើសយុទ្ធសាស្ត្រក្នុងការជួបប្រជុំ ត្រូវតែបានធ្វើការផ្សព្វផ្សាយជាសាធារណៈ។ | |
| ៦៧(ឃ) | គ្រឿងឧបករណ៍ដែលមានគ្រោះថ្នាក់តិចដល់ជីវិត៖ វគ្គបណ្តុះបណ្តាលសម្រាប់ការអនុវត្តច្បាប់ត្រូវមានបញ្ចូលការប្រើប្រាស់គ្រឿងឧបករណ៍ដែលមានគ្រោះថ្នាក់តិចដល់ជីវិតស្របច្បាប់ និងសមស្របទៅលើហ្វូងមនុស្ស។ | |
| ៦៧(ឃ) | គ្រឿងឧបករណ៍ការពារ៖មន្ត្រីអនុវត្តច្បាប់ត្រូវទទួលការបណ្តុះបណ្តាលត្រឹមត្រូវអំពីការប្រើប្រាស់វា និងត្រូវទទួលបានការណែនាំច្បាស់ថា គ្រឿងឧបករណ៍ដូចនេះត្រូវបានប្រើប្រាស់សម្រាប់ជាឧបករណ៍ការពារតែប៉ុណ្ណោះ។ | |
| ៦៧(ឃ) | រដ្ឋ ត្រូវតាមដានពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាល ដើម្បីបង្ការការរំលោភ បំពាន និងការប្រើប្រាស់អាវុធ និងយុទ្ធសាស្ត្រមិនត្រឹមត្រូវ។ | |
| ៦៧(ង) | កាំភ្លើងស្វ័យប្រវត្តិមិនត្រូវប្រើប្រាស់ក្នុងការគ្រប់គ្រងការជួបប្រជុំឡើយ ទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ | |

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៦៧(ច) | ប្រព័ន្ធអាវុធស្វយ័តដែលគ្មានមនុស្សត្រួតពិនិត្យត្រឹមត្រូវ ត្រូវបានហាមឃាត់។ | |
| ៦៧(ច) | បទបញ្ជាត្រូវបានដាក់ចេញ ដើម្បីធានាថា កម្លាំងដែលគ្រប់គ្រងពីចម្ងាយត្រូវបានប្រើប្រាស់ដោយមានការប្រុងប្រយ័ត្នបំផុតតែប៉ុណ្ណោះ។ | |
| ៦៧(ឆ) | គោលការណ៍ណែនាំទូលំទូលាយស្តីពីការបំបែកហ្វូងការជួបប្រជុំត្រូវបានបង្កើតឡើងស្របតាមច្បាប់និងគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ ហើយត្រូវតែបានយកមកអនុវត្ត។ | |
| ៦៧(ឆ) | គោលការណ៍ណែនាំស្តីពីការបំបែកការជួបប្រជុំ ផ្តល់ការណែនាំជាក់ស្តែងដល់មន្ត្រីអនុវត្តច្បាប់ ដោយរៀបរាប់លម្អិតអំពីកាលៈទេសៈដែលចាំបាច់ដើម្បីបំបែក គ្រប់វិធានការទាំងអស់ដែលនឹងត្រូវចាត់ឡើងមុនពេលនឹងសម្រេចបំបែក (រាប់ទាំងវិធានការបន្ថយការរីករាយដាល) និងនរណាអាចនឹងចេញបញ្ជាឲ្យបំបែក។ | |
| ៦៧(ឆ) | គោលការណ៍ណែនាំស្តីពីការបំបែក ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ | |
| ៦៧(ជ) | រដ្ឋបានបង្កើតឲ្យមានប្រព័ន្ធដ៏មានប្រសិទ្ធភាពសម្រាប់តាមដាន និងរាយការណ៍អំពីការប្រើប្រាស់កម្លាំង។ | |
| ៦៧(ជ) | ព័ត៌មានពាក់ព័ន្ធ រាប់ទាំងស្ថិតិអំពីថាតើកម្លាំងត្រូវបានប្រើប្រាស់នៅពេលណា និងប្រឆាំងនឹងអ្នកណា គឺងាយស្រួលទទួលបានពីសាធារណៈជន ។ | |
| ៦៧(ឈ) | ការត្រួតពិនិត្យមើលប្រកបដោយប្រសិទ្ធភាពត្រូវបានធ្វើឡើងដើម្បីហាមឃាត់ការជួញដូរគ្រឿងឧបករណ៍គ្រប់គ្រងហ្វូងមនុស្ស រាប់ទាំងបច្ចេកវិទ្យាឃ្លាំមើល ប្រសិនជាហានិភ័យធ្ងន់ធ្ងរកើតមានដែលពួកគេអាច (នៅក្នុងបរិបទនៃការជួបប្រជុំ) ជួយសម្រួលដល់ការសម្លាប់មនុស្សខុសច្បាប់ ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប ឬការរំលោភបំពានផ្សេងទៀតលើសិទ្ធិមនុស្ស។ | |

**គោលការណ៍ណែនាំទីមួយនេះ**
**លេខសូចនាករដែលបានបំពេញ (ក្នុងចំណោម២០)** →

# គោលការណ៍ណែនាំ ទីប្រាំមួយ

"មនុស្សគ្រប់រូបមានសិទ្ធិសង្កេតការណ៍ ឃ្លាំមើល និងកត់ត្រា ការជួបប្រជុំ"

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ (សូមអានរបាយការណ៍នេះ ត្រង់កថាខណ្ឌទី៦៨-៧១)៖**

• មនុស្សគ្រប់រូបមានសិទ្ធិសង្កេតការណ៍ និងបន្តតាមឃ្លាំមើលការជួបប្រជុំ។

•មនុស្សគ្រប់រូបមានសិទ្ធិកត់ត្រាការជួបប្រជុំ ដែលរាប់ទាំងសិទ្ធិកត់ត្រា ឬថតសកម្មភាពប្រតិបត្តិការរបស់មន្ត្រីអនុវត្តច្បាប់។ មនុស្សគ្រប់រូបមានសិទ្ធិផងដែរក្នុងការកត់ត្រា ឬថតកិច្ចសន្ទនាអន្តរកម្ម ដែលខ្លួនត្រូវបានភ្នាក់ងាររដ្ឋណាមួយកត់ត្រា ឬថត។ រដ្ឋគួរការពារសិទ្ធិនេះ។

• រដ្ឋមានកាតព្វកិច្ចការពារសិទ្ធិអ្នកឃ្លាំមើលការជួបប្រជុំ។ នេះរាប់ទាំងការគោរព និងជួយសម្រួលដល់សិទ្ធិសង្កេតការណ៍ និងឃ្លាំមើលគ្រប់ទិដ្ឋភាពទាំងអស់នៃការជួបប្រជុំ ស្ថិតក្នុងការរឹតត្បិតដែលអនុញ្ញាតដ៏ចង្អៀតដូចមានចែងក្នុងមាត្រា១៩(៣) នៃកតិកាសញ្ញា ICCPR។

• រដ្ឋគួរធ្វើការស៊ើបអង្កេតឲ្យបានពេញលេញនូវករណីរំលោភសិទ្ធិមនុស្ស ឬករណីរំលោភបំពានទៅលើអ្នកឃ្លាំមើល ហើយគួរចាត់ការទៅតាមផ្លូវច្បាប់ និងដោះស្រាយសំណងឲ្យបានសមស្រប។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៧២(ក) | យុទ្ធសាស្ត្រចូលរួមពីសហគមន៍ដ៏ទូលំទូលាយមួយត្រូវបានបង្កើតឡើង ដែលមានដាក់បញ្ចូលកម្មវិធី និងគោលនយោបាយដែលបានតាក់តែងឡើងដើម្បីកសាងការជឿទុកចិត្តគ្នា និងការទំនាក់ទំនងគ្នាក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកឃ្លាំមើលការជួបប្រជុំដទៃទៀត។ | |
| ៧២(ខ) | ការទំនាក់ទំនង៖ អាជ្ញាធរត្រូវចូលរួមសកម្មភាពបង្ការជាមុនជាមួយអ្នកឃ្លាំមើលដោយប្រាស្រ័យទាក់ទងគ្នាជាប់ជាប្រចាំ នៅមុនពេល ក្នុងពេល និងក្រោយពេលការជួបប្រជុំ។ | |
| ៧២(ខ) | លទ្ធភាពទទួលព័ត៌មាន និងការចែកចាយព័ត៌មាន៖ អាជ្ញាធរត្រូវផ្តល់ យ៉ាងសកម្មជាមុននូវលទ្ធភាព និងព័ត៌មានទៅដល់សមាជិកនៃប្រព័ន្ធផ្សព្វផ្សាយ និងអ្នកឃ្លាំមើលដទៃទៀត។ | |
| ៧២(ខ) | អាជ្ញាធរត្រូវពិចារណា និងឆ្លើយតបចំពោះរបាយការណ៍របស់អ្នកឃ្លាំមើល ក្រោយការជួបប្រជុំ។ | |
| ៧២(គ) | អាជ្ញាធរត្រូវជូនដំណឹងឲ្យបានទៀតទាត់ដល់ស្ថាប័នសិទ្ធិមនុស្សជាតិ ឬស្ថាប័នត្រួតពិនិត្យឯករាជ្យពាក់ព័ន្ធដទៃទៀត អំពីការជួបប្រជុំដែលនឹងកើតមាន ហើយត្រូវជួយសម្រួលលទ្ធភាពតាមលក្ខខណ្ឌតម្រូវ ដើម្បីអាចឲ្យពួកគេធ្វើការឃ្លាំមើលបាន។ | |

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៧២(ឃ) | ការជ្រៀតជ្រែកណាមួយក្នុងការកត់ត្រា ឬថតការជួបប្រជុំ រាប់ទាំងការរឹបអូស ឬបំផ្លាញគ្រឿងឧបករណ៍ណាមួយ ត្រូវបានហាមឃាត់ដោយច្បាប់លើកលែងតែអនុវត្តតាមដីការបស់ចៅក្រម ប្រសិនជាចៅក្រមចាត់ទុកថាវាមានតម្លៃជាភស្តុតាងក្នុងសវនាការ។ | |

**គោលការណ៍ណែនាំទីប្រាំមួយៈ**
**លេខសូចនាករដែលបានបំពេញ (ក្នុងចំណោម ៦)** →

# គោលការណ៍ណែនាំ ទីប្រាំពីរ

“ការប្រមូលព័ត៌មានបុគ្គលទាក់ទង និងការជួបប្រជុំ មិនត្រូវជ្រៀតជ្រែកដល់សិទ្ធិឯកជន និងសិទ្ធិដទៃទៀត ដោយគ្មានការអនុញ្ញាតឡើយ”

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ (សូមអានរបាយការណ៍នេះ ត្រង់កថាខណ្ឌទី៧៣-៧៧)៖**

•ការប្រមូល និងការចាត់ការដោយអាជ្ញាធរនូវទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គល ដូចជាតាមរយៈឧបករណ៍ថតសម្លេង ទូរទស្សន៍ បញ្ជូនរូបភាពពីកាមេរ៉ាមួយ ឬច្រើន និងការតាមឈ្លបមើលជាសម្ងាត់ ត្រូវតែគោរពតាមការការពារប្រឆាំងនឹងការជ្រៀតជ្រែកសិទ្ធិឯកជនតាមអំពើចិត្ត ឬដោយខុសច្បាប់។

•ច្បាប់ និងគោលនយោបាយគ្រប់គ្រងការប្រមូល និងការចាត់ការព័ត៌មានទាក់ទងនឹងការជួបប្រជុំ ឬអ្នករៀបចំ និងអ្នកចូលរួមក្នុងការជួបប្រជុំ ត្រូវតែបញ្ចូលនីត្យានុកូលភាព ភាពចាំបាច់ និងការធ្វើតេស្តសាកល្បងពីភាពសមាមាត្រ។

•ការរឹតត្បិតលទ្ធភាពទទួលបានព័ត៌មាន ឬការបញ្ចេញមតិតាមអនឡាញត្រូវតែចាំបាច់ និងសមាមាត្រ និងត្រូវតែអនុវត្តដោយស្ថាប័នមួយដែលឯករាជ្យពីឥទ្ធិពលនយោបាយ ពាណិជ្ជកម្ម ឬឥទ្ធិពលដទៃផ្សេងទៀត ដែលខុសច្បាប់ ហើយគួរតែមានការធានាការពារគ្រប់គ្រាន់ប្រឆាំងនឹងការរំលោភបំពាន។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៧៨(ក) | ច្បាប់តម្រូវថា សាធារណៈជនត្រូវតែទទួលដំណឹងនៅពេលដែលពួកគេត្រូវបាន ឬអាចត្រូវថតសម្លេងអំឡុងពេលជួបប្រជុំ។ ឧទាហរណ៍នេះអាចតម្រូវឲ្យមានការបិទផ្សាយជាបណ្ដោះអាសន្ននៅតាមបណ្ដោយផ្លូវដែលគ្រោងធ្វើការជួបប្រជុំ ដោយបង្ហាញពីកាមេរ៉ាបំពាក់ ឬប្រកាសផ្សាយជាសាធារណៈថា នឹងមានការថតរូបភាពពីលើអាកាសជាដើម។ | |
| ៧៨(ខ) | នៅពេលដែលបច្ចេកវិទ្យាជីវមាត្រ រួមទាំងកម្មវិធី (software) មើលស្គាល់មុខត្រូវបានយកមកប្រើប្រាស់នៅក្នុងបរិបទនៃការជួបប្រជុំ ការការពារមុតមាំ និងត្រឹមត្រូវដល់សិទ្ធិឯកជន និងសុវត្ថិភាព ត្រូវបានអនុវត្ត។ | |
| ៧៨(គ) | រដ្ឋ បានបង្កើតអនុវត្តច្បាប់ និងគោលនយោបាយដែលតម្រូវថា ព័ត៌មានផ្ទាល់ខ្លួនអាចត្រូវបានប្រមូល និងរក្សាទុកសម្រាប់តែគោលបំណងអនុវត្តច្បាប់ ស្របច្បាប់ និងធម្មានុរូបប៉ុណ្ណោះ។ | |
| ៧៨(គ)&(ឃ) | ច្បាប់ និងគោលនយោបាយទាក់ទងនឹងការប្រមូល និងការរក្សាទុកព័ត៌មានផ្ទាល់ខ្លួនបញ្ជាក់ជាក់លាក់ថា ព័ត៌មាន នឹងត្រូវបំផ្លាញចោលបន្ទាប់ពីរយៈពេលមួយសមស្របដូចមានចែងក្នុងច្បាប់។ ទោះជាយ៉ាងណាក៏ដោយ ក៏ព័ត៌មានពាក់ព័ន្ធគួរតែត្រូវបានរក្សាទុកប្រសិនបើព័ត៌មាននោះបង្ហាញពីការប្រើប្រាស់កម្លាំង ការឃុំខ្លួន ឬការចាប់ខ្លួន ឬការបំបែក ឬប្រសិនជាព័ត៌មាននោះទាក់ទងនឹងកម្មវត្ថុនៃបណ្ដឹង ឬប្រសិនជាមន្ត្រីអនុវត្តច្បាប់អាជ្ញាត្រួតពិនិត្យ ឬកម្មវត្ថុនៃព័ត៌មានមានការមន្ទិលសង្ស័យសមហេតុផលថាមានការប្រព្រឹត្តបទឧក្រិដ្ឋ ឬកំហុសឆ្គង។ | |

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៧៨(ខ) | រដ្ឋបានរៀបចំយន្តការផ្សេងៗដែលបុគ្គលអាចបញ្ជាក់ថាតើព័ត៌មានអ្វីខ្លះត្រូវបានរក្សាទុក ប្រសិនជាមាន និងផ្តល់លទ្ធភាពចូលពិនិត្យមើលប្រកបដោយប្រសិទ្ធភាព សម្រាប់ធ្វើបណ្តឹងទាក់ទងនឹងការប្រមូល ការរក្សាទុក និងការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ហើយដែលអាចនាំឲ្យមានការកែតម្រូវ ឬការលុបចោល។ | |
| ៧៨(ច) | ប្រព័ន្ធត្រួតពិនិត្យបែបប្រជាធិបតេយ្យច្បាស់លាស់សម្រាប់ការឈ្លបមើលជាសម្ងាត់ត្រូវបានរៀបចំឲ្យមានតាមរយៈច្បាប់ បទបញ្ញា និងគោលនយោបាយ ស៊ីសង្វាក់គ្នា។ បញ្ញត្តិទាំងនេះត្រូវដាក់បញ្ចូលយ៉ាងច្បាស់នូវភាពចាំបាច់ ភាពសមាមាត្រ និងតេស្តសាកល្បង ហើយចែងយ៉ាងច្បាស់លាស់ថាតើហានិភ័យនៃការជ្រៀតជ្រៀតនឹងត្រូវវាយតម្លៃ និងគ្រប់គ្រងយ៉ាងដូចម្តេច។ | |
| ៧៨(ច) | ប្រព័ន្ធត្រួតពិនិត្យសម្រាប់ការឈ្លបមើលជាសម្ងាត់ រួមបញ្ចូលទាំងដំណើរ ការពិនិត្យផ្ទៃក្នុង ក៏ដូចជាការត្រួតពិនិត្យដោយស្ថាប័ន ឬអង្គការឯករាជ្យ ពីខាងក្រៅ។ | |
| ៧៨(ច) | តម្រូវឲ្យមានការអនុញ្ញាតពីអាជ្ញាធរតុលាការ ចំពោះសកម្មភាពតាមឈ្លបមើលជាសម្ងាត់នៅក្នុងបរិបទនៃការជួបប្រជុំ។ | |

**គោលការណ៍ណែនាំលេខប្រាំ៖**

**លេខសូចនាករដែលបានបំពេញ (ក្នុងសូចនាករទាំង៨)** →

# គោលការណ៍ណែនាំ ទីប្រាំបី

"មនុស្សគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងការជួបប្រជុំ"

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ (សូមអានរបាយការណ៍នេះ ត្រង់កថាខណ្ឌទី៧៩-៨១)៖**

- សាធារណៈជនគួរតែមានសិទ្ធិទទួលបានព័ត៌មានដោយស្រួល ឆាប់រហ័ស មានប្រសិទ្ធភាព និងជាក់ស្តែងទាក់ទងការជួបប្រជុំ។ ច្បាប់ដែលជួយសម្រួលដល់សិទ្ធិនេះគួរត្រូវបានផ្អែកលើគោលការណ៍លាតត្រដាងព័ត៌មានជាអតិបរមាដែលបង្កើតការសន្មតថា ព័ត៌មានចូលមើលបានស្ថិតក្នុងប្រព័ន្ធអញ្ញត្រកម្ម ដែលមានលក្ខណៈតូចចង្អៀតតែប៉ុណ្ណោះ។
- អញ្ញត្រកម្មគួរអនុវត្តតែក្នុងករណីដែលមានហានិភ័យនៃគ្រោះថ្នាក់ចម្បងៗទៅលើផលប្រយោជន៍ដែលបានការពារ ហើយក្នុងករណីដែលគ្រោះថ្នាក់នោះមានទំហំធំជាងប្រយោជន៍សាធារណៈទូទៅ ដើម្បីលទ្ធភាពទទួលបានព័ត៌មាន។

- បន្ទុកគួរតែលើអាជ្ញាធរសាធារណៈក្នុងការបង្ហាញថា ព័ត៌មានស្ថិតក្នុងវិសាលភាពនៃអញ្ញត្រកម្ម។ ការសម្រេចរបស់ខ្លួនត្រូវតែស្ថិតក្រោមការត្រួតពិនិត្យ និងការពិនិត្យឡើងវិញ។
មើលហើយគួរចាត់ការទៅតាមផ្លូវច្បាប់ និងដោះស្រាយសំណងឲ្យបានសមស្រប។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៨២(ក) | រដ្ឋត្រូវផ្សព្វផ្សាយឲ្យបានសកម្មជាមុននូវព័ត៌មានសំខាន់ៗទាក់ទងនឹងការគ្រប់គ្រងការជួបប្រជុំ រាប់បញ្ចូលទាំងព័ត៌មានទាក់ទងនឹងការទទួលខុសត្រូវ និងនិតិវិធីរបស់ភ្នាក់ងារ និងស្ថាប័នទាំងឡាយដែលគ្រប់គ្រងការជួបប្រជុំ គោលនយោបាយ នីតិវិធីប្រតិបត្តិការតាមបទដ្ឋាន និងគោលនយោបាយ រាប់ទាំងក្រមសីលធម៌ ការដឹកនាំការគ្រប់គ្រងការជួបប្រជុំ ប្រភេទឧបករណ៍ដែលត្រូវបានប្រើប្រាសក្នុងការគ្រប់គ្រងការជួបប្រជុំ ព័ត៌មានស្តីពី ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ និងព័ត៌មានស្តីពីរបៀបចូលកាន់ដំណើរការគណនេយ្យភាព។ | |
| ៨២(ខ) | ច្បាប់ទូលំទូលាយ ឧទាហរណ៍ ច្បាប់ស្តីពីសេរីភាពព័ត៌មាន ត្រូវតែមានដើម្បីសម្រួលដល់សិទ្ធិទទួលបានព័ត៌មានជាសាធារណៈ។ | |
| ៨២(ខ) | ច្បាប់ណាមួយដែលជួយសម្រួលដល់សិទ្ធិទទួលបានព័ត៌មានជាសាធារណៈត្រូវតែផ្អែកលើគោលការណ៍លាតត្រដាងព័ត៌មានជាអតិបរមា។ | |
| ៨២(ខ) | រដ្ឋត្រូវគ្រប់គ្រងព័ត៌មានពាក់ព័ន្ធឲ្យបានទូលំទូលាយ និងងាយស្រួលទាញយកប្រើប្រាស់។ | |
| ៨២(ខ) | អាជ្ញារដ្ឋត្រូវឆ្លើយតបភ្លាមៗ និងយ៉ាងពេញលេញចំពោះរាល់ការស្នើសុំព័ត៌មានផ្សេងៗ។ | |

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៨២(គ) | យន្តការការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពមួយត្រូវតែមាន ដែលមានអំណាចទទួល និងស៊ើបអង្កេតបណ្តឹង និងចេញបញ្ជាជាប់កាតព្វកិច្ចសម្រាប់ការផ្សព្វផ្សាយព័ត៌មានដែលជួយដល់អ្នកដាក់ពាក្យបណ្តឹង ឬអ្នកប្តឹង។ | |

**គោលការណ៍ណែនាំលេខប្រាំ៖**

**លេខសូចនាករដែលបានបំពេញ (ក្នុងសូចនាករទាំង៨)** →

# គោលការណ៍ណែនាំ
# ទីប្រាំបួន

"សហគ្រាសធុរកិច្ចមានទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស ក្នុងបរិបទនៃការជួបប្រជុំ"

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ (សូមអានរបាយការណ៍នេះ ត្រង់កថាខណ្ឌទី៨៣-៨៧)៖**

•សហគ្រាសធុរកិច្ចមានទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស រាប់ទាំងនៅក្នុងបរិបទនៃការជួបប្រជុំផងដែរ។ ការនេះ តម្រូវឲ្យធុរកិច្ចជៀសវាងការបង្ករ ឬការចូលរួមចំណែកឲ្យមានផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សតាមរយៈសកម្មភាពរបស់ខ្លួនផ្ទាល់ ហើយត្រូវដោះស្រាយផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សដែលខ្លួនពាក់ព័ន្ធ។

• សិទ្ធិទាក់ទងការជួបប្រជុំ អាចតម្រូវឲ្យមានវិធានការវិជ្ជមាន សូម្បីតែក្នុងវិស័យទំនាក់ទំនងរវាងបុគ្គលនិងបុគ្គលក្តី។

•អង្គភាពធុរកិច្ចគួរអនុវត្តគោលការណ៍សិទ្ធិមនុស្សដោយយកចិត្តទុកដាក់ ហើយក្នុងករណីមានផលប៉ះចម្បងលើការជួបប្រជុំ និងសិទ្ធិទាំងឡាយដែលពាក់ព័ន្ធ ត្រូវធ្វើការបន្ថយហានិភ័យទាំងនេះ។

• រដ្ឋមានភារកិច្ចចាត់វិធានការសមស្របដើម្បីបង្ការ ស៊ើបអង្កេត និងផ្តល់ការដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះកំហុសឆ្គងដែលពាក់ព័ន្ធ ដែលបង្កឡើងដោយសហគ្រាសធុរកិច្ច ហើយត្រូវចាប់ភាគីឯកជននោះឲ្យទទួលខុសចំពោះការបង្ករ ឬការរួមចំណែកដកហូតជីវិតដោយបំពាននៅក្នុងដែនដី ឬដែនសមត្ថកិច្ចរបស់រដ្ឋមួយ។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៨៨(ក) | រដ្ឋត្រូវការពារបុគ្គលឲ្យរួចផុតពីការជ្រៀតជ្រែកសិទ្ធិរបស់ពួកគេនៅក្នុងបរិបទនៃជួបប្រជុំពីសំណាក់សហគ្រាសធុរកិច្ច រាប់ទាំងការចាត់វិធានការឲ្យគោរពតាមការទទួលខុសត្រូវដូចបានស្រាយបំភ្លឺនៅក្នុងគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស។ | |
| ៨៨(ខ) | ប្រសិនជាទីលានជាកម្មសិទ្ធិបុគ្គលឯកជនបើកឲ្យសាធារណជនទូទៅ និងបម្រើមុខងារស្រដៀងគ្នានឹងទីលានសាធារណៈ ត្រូវចាត់ទុកទីលាននោះជាទីលានជាសាធារណៈ សម្រាប់គោលបំណងអនុវត្តសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងការបញ្ចេញមតិ។ | |
| ៨៨(គ) | រដ្ឋបានដាក់ចេញនូវការការពារសម្រាប់អ្នករៀបចំ និងអ្នកចូលរួមការជួបប្រជុំ ឲ្យរួចផុតពីបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងដោយមិនចាំបាច់ ឬក្នុងគោលបំណងបំភ័យការចូលរួមរបស់សាធារណៈជន។ | |

**គោលការណ៍ណែនាំលេខប្រាំ៖**
**លេខសូចនាករដែលបានបំពេញ (ក្នុងសូចនាករទាំង៨)** →

# គោលការណ៍ណែនាំ ទី៨ប់

"រដ្ឋ និងអង្គការរបស់ខ្លួន ត្រូវទទួលខុសត្រូវ ចំពោះសកម្មភាពរបស់ខ្លួនទាក់ទង នឹងការជួបប្រជុំ"

**បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ (សូមអានរបាយការណ៍នេះ ត្រង់កថាខណ្ឌទី៨៩-៩៥)៖**

• រដ្ឋមានកាតព្វកិច្ចផ្តល់ឲ្យអ្នកទាំងឡាយដែលទទួរងការរំលោភសិទ្ធិក្នុងបរិបទនៃការជួបប្រជុំ នូវការដោះស្រាយសំណងសមរម្យ ប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចដែលមានអំណាចពង្រឹងការអនុវត្តដំណោះស្រាយនោះ។

• រដ្ឋត្រូវស៊ើបអង្កេតករណីចោទប្រកាន់ណាមួយនៃការរំលោភបំពានក្នុងបរិបទនៃការជួបប្រជុំឲ្យឆាប់រហ័ស និងមានប្រសិទ្ធភាព តាមរយៈស្ថាប័នដែលឯករាជ្យ និងមិនលំអៀង។

• ការទទួលខុសត្រូវគួរតែពង្រីកទៅដល់មន្ត្រីដែលគ្រប់គ្រងលើបទបញ្ជា ប្រសិនបើពួកគេមិនបានអនុវត្តការគ្រប់គ្រង និងបទបញ្ជាប្រកបដោយប្រសិទ្ធភាពទេនោះ។

• ព្រះរាជអាជ្ញាគួរអនុវត្តមុខងាររបស់ខ្លួនដោយមិនលំអៀង និងដោយគ្មានការរើសអើង ហើយគួរផ្តោតការយកចិត្តទុកដាក់ត្រឹមត្រូវក្នុងការចោទប្រកាន់តាមផ្លូវច្បាប់ចំពោះបទឧក្រិដ្ឋ ដែលមន្ត្រីសាធារណៈបានប្រព្រឹត្ត។

• ចុងចោទគួរត្រូវបាននាំខ្លួននៅចំពោះមុខតុលាការ ឬសាលាក្តីសាមញ្ញ ហើយត្រូវទទួលបានការការពារផ្នែកការជំនុំជម្រះក្តីដោយត្រឹមត្រូវ ដែលធានាការពារដោយច្បាប់អន្តរជាតិ។

• រដ្ឋត្រូវផ្តល់សំណងឲ្យជនរងគ្រោះចំពោះទង្វើ ឬការខកខានមិនបានបំពេញកាតព្វកិច្ចដែលអាចបង្កឡើងក្នុងនាមរដ្ឋ ហើយនាំឲ្យមានការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៩៦(ក) | មន្ត្រីអនុវត្តច្បាប់មិនត្រូវមានអភ័យឯកសិទ្ធិរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីចំពោះករណីប្រព្រឹត្តកំហុសឆ្គងក្នុងច្បាប់ ឬក្នុងការអនុវត្តជាក់ស្តែងឡើយ។ | |
| ៩៦(ខ) | រដ្ឋបានបង្កើត និងផ្តល់មូលនិធិកម្រិតបន្ថែមនៃការត្រួតពិនិត្យមិនមែនតុលាការ រាប់ទាំងដំណើរការស៊ើបអង្កេតផ្ទៃក្នុងមួយប្រកបដោយប្រសិទ្ធភាព។ | |
| ៩៦(ខ) | រដ្ឋបានបង្កើត និងផ្តល់មូលនិធិដល់ស្ថាប័នឯករាជ្យដែលបង្កើតដោយច្បាប់ដើម្បីត្រួតពិនិត្យការងារនគរបាល។ | |
| ៩៦(ខ) | ប្រសិនជាមានហេតុផលជឿជាក់បានថាមានបទល្មើសមួយត្រូវបានប្រព្រឹត្ត បញ្ហានោះត្រូវតែបានបញ្ជូនភ្លាមៗដោយយន្តការត្រួតពិនិត្យមិនមែនតុលាការ ទៅស្ថាប័នអយ្យការដើម្បីធ្វើការស៊ើបអង្កេតពេញលេញ និងត្រឹមត្រូវ។ | |

| កំណត់ត្រាលេខ* | សូចនាករ | បានអនុវត្តឬទេ? |
|---|---|---|
| ៩៦(គ) | មន្ត្រីអនុវត្តច្បាប់ណាម្នាក់ដែលស្ថិតក្រោមការស៊ើបអង្កេតផ្ទៃក្រៅក្តី ឬផ្ទៃក្នុងក្តី មិនអាចត្រូវបានដាក់ពង្រាយនៅតាមគោលដៅឡើយ រហូតដល់ការស៊ើបអង្កេតចប់សព្វគ្រប់ ហើយមន្ត្រីនោះត្រូវបានជម្រះអស់កំហុសឆ្គង។ | |
| ៩៦(ឃ) | រដ្ឋបានផ្តល់អាណត្តិទូលំទូលាយដល់ស្ថាប័នត្រួតពិនិត្យឯករាជ្យមួយ ដែលមានសមត្ថកិច្ច និងអំណាចការពារសិទ្ធិប្រកបដោយប្រសិទ្ធភាពនៅក្នុងបរិបទនៃការជួបប្រជុំ។ | |
| ៩៦(ឃ) | ស្ថាប័នត្រួតពិនិត្យឯករាជ្យមានអាណត្តិស៊ើបអង្កេតបណ្តឹងពីសាធារណជន ទទួលយកការបញ្ជូនពីនគរបាល និងផ្តើមធ្វើការស៊ើបអង្កេតដោយផ្ទាល់ ប្រសិនជាបណ្តឹងនេះស្ថិតក្នុងផលប្រយោជន៍សាធារណៈដែលតម្រូវឲ្យធ្វើដូច្នេះ។ | |
| ៩៦(ឃ) | ស្ថាប័នត្រួតពិនិត្យឯករាជ្យ ស៊ើបអង្កេតគ្រប់ករណីទាំងអស់អំពីការប្រើប្រាស់កម្លាំងដោយមន្ត្រីអនុវត្តច្បាប់។ | |
| ៩៦(ឃ) | ស្ថាប័នត្រួតពិនិត្យមានអំណាចស៊ើបអង្កេតពេញលេញដែលមិនត្រូវបានកម្រិត កំណត់ក្នុងច្បាប់ ឬក្នុងការអនុវត្តជាក់ស្តែង។ | |
| ៩៦(ឃ) | ស្ថាប័នត្រួតពិនិត្យឯករាជ្យចាត់ការបណ្តឹងដោយមិនលំអៀង ត្រឹមត្រូវ឵ ឆាប់រហ័ស អនុលោមតាមលក្ខណៈវិនិច្ឆ័យច្បាស់លាស់។ | |
| ៩៦(ខ) | ទីភ្នាក់ងារអនុវត្តច្បាប់បន្តធ្វើការត្រួតពិនិត្យគ្នាទៅវិញទៅមកជាលក្ខណៈ មិត្តភក្តិលើការប្រតិបត្តិគ្រប់គ្រង ប្រសិនជាអាចធ្វើបាន ការពិនិត្យត្រូវបានធ្វើឡើងដោយភ្នាក់ងារអនុវត្តច្បាប់មួយផ្សេងទៀត។ | |
| ៩៦(ឆ) | រដ្ឋបានពិចារណាអំពីសក្តានុពលនៃបច្ចេកវិទ្យាព័ត៌មាន និងការទំនាក់ទំនងដូចជា ម៉ាស៊ីនថតរូបបំពាក់ជាប់នឹងខ្លួន ក្នុងការរួមចំណែកដល់ការទទួលខុសត្រូវចំពោះការរំលោភបំពានពីសំណាក់មន្ត្រីអនុវត្តច្បាប់នៅក្នុងបរិបទនៃការជួបប្រជុំ។ | |

**គោលការណ៍ណែនាំលេខប្រាំ៖**

**លេខសូចនាករដែលបានបំពេញ (ក្នុងសូចនាករទាំង១២)** →

# សិទ្ធិជួបប្រជុំរបស់ប្រទេសអ្នក

# ពិន្ទុ

ឈ្មោះប្រទេស: ........................................................... កាលបរិច្ឆេទដាក់ពិន្ទុ៖......................................

ដាក់ពិន្ទុដោយ (ស្ម័គ្រចិត្ត)៖ ..........................................

គោលការណ៍ណែនាំទីមួយ៖
កាតព្វកិច្ចគោរព
(ក្នុងចំណោម ១៥ពិន្ទុ)

គោលការណ៍ណែនាំទីពីរ៖
សិទ្ធិមិនអាចផ្ទេរឬលក់ដូរបាន
(ក្នុងចំណោម ១០ពិន្ទុ)

គោលការណ៍ណែនាំទីបី៖
ការរិតត្បិតមានកម្រិត
(ក្នុងចំណោម ១០ពិន្ទុ)

គោលការណ៍ណែនាំទីបួន៖
ការសម្របសម្រួល
(ក្នុងចំណោម ១០ពិន្ទុ)

គោលការណ៍ណែនាំទីប្រាំ៖
ការប្រើប្រាស់កម្លាំង
(ក្នុងចំណោម ២០ពិន្ទុ)

គោលការណ៍ណែនាំទីប្រាំមួយ៖
ការឃ្លាំមើល
(ក្នុងចំណោម ៦ពិន្ទុ)

គោលការណ៍ណែនាំទីប្រាំពីរ៖
សិទ្ធិឯកជន
(ក្នុងចំណោម ៨ពិន្ទុ)

គោលការណ៍ណែនាំទីប្រាំបី៖
លទ្ធភាពទទួលបានព័ត៌មាន
(ក្នុងចំណោម ៦ពិន្ទុ)

គោលការណ៍ណែនាំទីប្រាំបួន៖
ធុរកិច្ច
(ក្នុងចំណោម ៣ពិន្ទុ)

គោលការណ៍ណែនាំទីដប់៖
គណនេយ្យភាព
(ក្នុងចំណោម ១២ពិន្ទុ)

**សរុប៖ (ក្នុងចំណោម១០០ ពិន្ទុដែលអាចមាន)**

**អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ**

ស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម

freeassembly.net • facebook.com/mainakiai.sr • twitter.com/MainaKiai_UNSR • flickr.com/photos/mainakiai • ohchr.org
info@freeassembly.net • freeassembly@ohchr.org